# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Sep-2012, 10:18
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់អង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញាលើយុត្តិសាស្ត្រដែលបានលើកឡើងដោយមេធាវីការពារក្ដី អៀង ធីរិទ្ធ នៅក្នុងពេលសវនាការស្ដីពីសម្បទាក្នុងការចូលរួមសវនាការ នៅថ្ងៃសុក្រ ទី៣១ ខែសីហា ឆ្នាំ២០១២

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន
អៀង ធីរិទ្ធ

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael G.KARNAVAS
លោក គង់ សំអុន
Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS, QC

១. សហព្រះរាជអាជ្ញាដាក់ជូនសេចក្តីសង្កេតទាំងនេះ ដើម្បីជាជំនួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ និងដីកាសម្រេចជាបន្តបន្ទាប់ណាមួយដែលអាចនឹងកើតមាន។ ក្នុងដំណើរការសេចក្តីសន្និដ្ឋានបញ្ចប់នៅចំពោះមុខអង្គជំនុំជម្រះ កាលពីថ្ងៃសុក្រ ទី៣១ ខែសីហា ឆ្នាំ២០១២ មេធាវីការពារក្តី អៀង ធីរិទ្ធ សន្និដ្ឋានថា កូនក្តីរបស់ខ្លួន គួរត្រូវបានដោះលែងដោយគ្មានលក្ខខណ្ឌ។ ដើម្បីជាការគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន លោកស្រីមេធាវីបានលើកយោងករណីរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Radoslav Brdanin* *និង* *Momir Talić* ដោយបានថ្លែងថា:

> *យើងបានពិនិត្យមើលប្រភពច្បាប់មួយចំនួនដែលអាចជួយដល់អង្គជំនុំជម្រះនៅក្នុងគំនិតនេះ ហើយប្រហែលថា ករណីដែលមានការពាក់ព័ន្ធ ហើយវាមានសារៈសំខាន់ ដែលយើងខ្ញុំនឹងយោងទៅរកហ្នឹង រឿងក្តីប្រេឆានីន ហើយនិង រឿងក្តីថាលីក នៅតុលាការអន្តរជាតិ ដែលនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវី ជាសេចក្តីសម្រេចនិយាយអំពីសំណើសុំឱ្យដោះនៅក្រៅឃុំបណ្តោះអាសន្ន នៅខែកញ្ញា ឆ្នាំ២០០២។ ហើយនៅក្នុងករណីនេះ គឺករណីគំរូនេះគឺសំខាន់ណាស់ អង្គជំនុំជម្រះសាលាដំបូងនោះនិយាយថា នៅពេលដែលវាយតម្លៃថាតើត្រូវដោះលែង ឬមិនដោះលែងជនជាប់ចោទ អង្គជំនុំជម្រះត្រូវតែសង្កត់ឱ្យច្បាស់ទៅលើស្ថានភាពជាក់ស្តែងរបស់បុគ្គលដែលដាក់ពាក្យសុំនេះ។ ហើយជាផលលំបាក ខបញ្ញត្តិដែលនិយាយអំពីការដោះលែងក្រៅឃុំបណ្តោះអាសន្ននេះ គឺមិនអាចអនុវត្តដោយមានការណែនាំ។ ប៉ុន្តែត្រូវតែផ្អែកលើអង្គហេតុនៅក្នុងករណីជាក់លាក់នីមួយៗ។*
>
> *ហើយនៅក្នុងករណីនេះអង្គជំនុំជម្រះសាលាដំបូងបានបន្តសំរេចថា វិធានការនីតិវិធីមិនត្រូវយកមកដាក់ជាវិធានការដាច់ខាតអនុវត្ត គឺត្រូវប្រើវិធានការដែលស្រាលជាងទៅវិញទេ។ តុលាការជំរុញថា ត្រូវតែភ្ជាប់ទៅនឹងសច្ចធារណ៍នីរទោសហើយនិងអង្គហេតុនៃរឿង ខេស ហើយនឹងគោរពគោលការណ៍នៃសមមាត្រភាព និងធានាកិត្តិយសរបស់តុលាការដែលសំរេចក្នុង រឿងក្តីនេះផងដែរ។ អង្គជំនុំជម្រះនៅក្នុងរឿងក្តីនេះបានសំរេចថាបន្ទាប់តែធានានូវផលប្រយោជន៍ សាធារណៈ ជនរងគ្រោះ និងសាក្សីដែលសហការជាមួយសហព្រះរាជអាជ្ញានោះ ហើយនិងសិទ្ធរបស់ជនជាប់ចោទ ដែលត្រូវតែគោរពក្នុងលក្ខណៈមនុស្សធម៌ ហើយគោរពទៅតាមគោលការណ៍ ដោយការគោរពនូវកិត្យានុភាព និងសច្ចធារណ៍នីរទោស ដែលបញ្ជាក់ថាជនជាប់--ត្រូវដោះលែងជនជាប់ចោទដោយផ្អែកលើលក្ខណៈ សុខភាពជាក់ស្តែងរបស់គាត់។*
> *ហើយអង្គជំនុំជម្រះកាលនោះបញ្ជាក់ថា៖ "គឺគ្មានការសង្ស័យអ្វីទេនៅពេលលក្ខខណ្ឌសុខភាពវេជ្ជសាស្ត្រ ដែលក្លាយទៅជាមិនអាចឱ្យគាត់រងការឃុំខ្លួនបានទេ ។ អង្គជំនុំជម្រះហើយ និង*

*តុលាការផ្សេង សាលាក្តីណាផ្សេងក្នុងការអន្តរាគមន៍ដោយផ្អែកលើគោលការណ៍នៃច្បាប់មនុស្សធម៌នោះ ហើយត្រូវផ្តល់ដំណោះស្រាយដែលមានភាពចាំបាច់”។ ហើយក្នុងករណីនោះគឺក្នុងរយៈពេលសមស្រប ជនជាប់ចោទត្រូវបានដោះលែង ដោយគ្មានលក្ខខណ្ឌអ្វីទេ[1]* ។

២. សហព្រះរាជអាជ្ញាកត់សំគាល់ថា ការបង្ហាញរបស់មេធាវីការពារក្តីនូវប្រភេទនៃការដោះលែងជាបណ្តោះអាសន្នដោយគ្មានលក្ខខណ្ឌ ក្នុងរឿងក្តី *Talić* មិនស្របទៅតាមសេចក្តីសម្រេចដែលបានលើកយោង និងផ្តល់ជូនដោយមេធាវីការពារក្តីរូបនេះទេ បន្ទាប់ពីសវនាការ។ ដូចសេចក្តីសម្រេចនេះបានបង្ហាញច្បាស់ហើយ និងដូចដែលជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា លោក Abdulhak បានបញ្ជាក់ក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់គាត់រួចហើយ[2] គឺជាជាប់ចោទ *Talić* ត្រូវបានដោះលែងដោយត្រូវឲ្យស្ថិតនៅក្រោមលក្ខខណ្ឌជាច្រើន[3]។

៣. សហព្រះរាជអាជ្ញាធ្វើសេចក្តីសង្កេតនេះឡើងគឺដើម្បីធានាថា កំណត់ហេតុនៃយុត្តិសាស្ត្រនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺពិតជាការត្រឹមត្រូវ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក William SMITH** សហព្រះរាជអាជ្ញារង | | |

[1] ពង្រាងប្រតិចារិក ថ្ងៃទី៣១ សីហា ២០១២ ត្រង់ទំព័រ១២៩ ពីជួរបន្ទាត់ទី២៣-ទំព័រ១៣១ ជួរបន្ទាត់ទី៩ (ភាសាអង់គ្លេស), ទំព័ទី១៤ ពីជួរបន្ទាត់ទី២៣-ទំព័រ១៣១ ជួរបន្ទាត់ទី ៩ (ភាសាបារាំង), ទំព័រ៩៥ ជួរបន្ទាត់ទី១៧-ទំព័រ៩៦ ជួរបន្ទាត់ទិ១៧ (ភាសាខ្មែរ)។

[2] សេចក្តីព្រាងប្រតិចារឹក, ៣១ សីហា ២០១២ ត្រង់ទព័រ១០៣ បន្ទាត់២-ទំព័រ១៣ (អង់គ្លេស), ទំព័រ៩៦ បន្ទាត់២០-ទំព័រ៩៧ បន្ទាត់៥ (បារាំង), ទំព័រ៩៣ បន្ទាត់១៤-បន្ទាត់២១ (ខ្មែរ)។

[3] *រដ្ឋអាជ្ញា ទល់នឹង Radoslav Brdanin និង Momir Talić*, សំណុំរឿងលេខៈ IT-99-36, សេចក្តីសម្រេចលើញត្តិស្នើសុំឲ្យដោះលែងជាបណ្តោះអាសន្នជនជាប់ចោទ Momir Talić (អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY), ២០ កញ្ញា ២០០២ ត្រង់កថាខណ្ឌ១៣-១៦។